# របាយការណ៍ក្រសួងការបរទេសសហរដ្ឋអាមេរិក

# របាយការណ៍ស្តីពីការជួញដូរមនុស្សឆ្នាំ ២០១៩

# ប្រទេសកម្ពុជា - (លំដាប់ថ្នាក់ទី ២ ក្នុងបញ្ជីតាមដាន)

រដ្ឋាភិបាលកម្ពុជាមិនបានគោរពបានពេញលេញតាមបទដ្ឋានអប្បបរមាក្នុងការលុបបំបាត់ការជួញដូរ មនុស្សទេ ។ ទោះជាយ៉ាងណាក្តី ក៏រដ្ឋាភិបាលកំពុងតែខិតខំច្រើនគួរសមក្នុងការប្រយុទ្ធប្រឆាំងនឹងការជួញដូរមនុស្ស ។ រដ្ឋាភិបាលបានបង្ហាញឲ្យឃើញនូវការបង្កើនការខិតខំ នៅក្នុងរយៈកាលនៃរបាយការណ៍នេះ ដូចជាបានបន្តកាត់ទោសនិងដាក់ទោសជនល្មើស បង្កើនការបណ្តុះបណ្តាលសមត្ថកិច្ច ធ្វើការលើកកម្ពស់ការយល់ដឹងពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព ទៅកាន់ប្រទេសគោលដៅចម្បង។ តែរដ្ឋាភិបាលមិនបានបង្ហាញឲ្យឃើញថាបានបង្កើនការខិតខំទេ បើប្រៀបធៀបនឹងរយៈកាលនៃរបាយការណ៍លើកមុន។ អាជ្ញាធរមិនបានប្រមូលព័ត៌មានឲ្យបានគ្រប់គ្រាន់ ឬចែករំលែកព័ត៌មានគន្លឹះ ស្តីពីការងារពង្រឹងការអនុវត្តច្បាប់ទេ។ អំពើពុករលួយនៅតែធ្វើឲ្យរាំងស្ទះដល់ការងាររបស់សមត្ថកិច្ច ដំណើរការកាត់ក្តីជនល្មើស និងការផ្តល់សេវាដល់ជនរងគ្រោះ។ នៅចំពោះមុខ កង្វះការគ្រប់គ្រង និងវិធានការចាប់ឲ្យទទួលខុសត្រូវរបស់រដ្ឋាភិបាល អាជ្ញាធរមិនបានធ្វើការស៊ើបអង្កេតលើរបាយការណ៍ដែលគួរឲ្យទុកចិត្តបានពាក់ព័ន្ធការឃុបឃិតរបស់មន្ត្រី ជាមួយឈ្មួញខិលខូច ដែលបានធ្វើឲ្យបុរស ស្ត្រី និងកុមាររាប់ពាន់នាក់នៅទូទាំងប្រទេស រងការជួញដូរមនុស្ស តាមរយៈការបង្ខិតបង្ខំដោយសារបំណុល ពិសេសនៅតាមកន្លែងឡឥដ្ឋ។ នៅក្នុងករណីធំៗមួយចំនួន រដ្ឋាភិបាលបានប្រើច្បាប់ប្រឆាំងការជួញដូរ និងធនធានសម្រាប់ការងារពង្រឹងការអនុវត្តច្បាប់ ដើម្បីដៅទៅលើមន្ត្រីគណបក្សប្រឆាំង និងអ្នកដទៃទៀតដែលមិនពាក់ព័ន្ធនឹងការជួញដូរ ក្នុងបំណងចងក្រងឯកសារស្តីពីករណីជួញដូររបស់ប្រទេសកម្ពុជា។ អាជ្ញាធរមិនបានចេញការណែនាំផ្លូវការដែលអនុញ្ញាតឲ្យប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ នៅក្នុងប្រតិបត្តិការប្រឆាំងនឹងការជួញដូរទេ។ កត្តានេះបន្តធ្វើអោយមានឧបសគ្គដល់លទ្ធភាពរបស់មន្ត្រី នៅក្នុងការចាប់ឲ្យជនប្រព្រឹត្តការជួញដូរផ្លូវភេទទទួលខុសត្រូវ។ ដូច្នេះ ប្រទេសកម្ពុជាត្រូវបានបញ្ចុះលំដាប់ថ្នាក់មកលំដាប់ទី ២ ក្នុងបញ្ជីតាមដាន។

**អនុសាសន៍ជាអាទិភាព៖** ដោយគោរពដំណើរការត្រឹមត្រូវ បង្កើនការខិតខំក្នុងការស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស និងដាក់ទណ្ឌកម្មចំពោះជនល្មើសក្នុងការជួញដូរផ្លូវភេទនិងជួញដូរពល

កម្ម រួមទាំងមន្ត្រីឃុបឃិត ដោយដាក់ទោសឲ្យជាប់ពន្ធនាគារធ្ងន់ធ្ងរ  អនុញ្ញាតឲ្យមានការប្រើបច្ចេកទេសស៊ើបអង្កេតសម្ងាត់ នៅក្នុងការអនុវត្តច្បាប់ប្រឆាំងការជួញដូរ អនុវត្តពេញលេញនូវពិធីសារថ្មីទូទាំងប្រទេសសំរាប់រកមើលជនរងគ្រោះនៅក្នុងចំណោមក្រុមដែលងាយរងគ្រោះ ហើយបង្រៀនមន្ត្រីឲ្យយល់ពីខដែលចែងនៅក្នុងច្បាប់នេះ បង្កើនការធ្វើអធិការកិច្ចការងារ នៅកន្លែងការងារដែលមានការប្រឈមខ្លាំងពិសេសនៅតាមឡឥដ្ឋ កន្លែងនេសាទ និងចំការធំៗ ដោយផ្តោតសំខាន់លើការរកមើលទាសភាពបំណុល បង្កើនសេវាដល់ជនរងគ្រោះជាបុរស ពិសេសបុរសដែលត្រូវបានគេកេងប្រវ័ញ្ចនៅក្នុងឧស្សាហកម្មនេសាទ បង្កើនការតាមមើល និងត្រួតពិនិត្យលើស្ថាប័នឲ្យកម្ចី ដោយរួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនឹងការបង្ខំដោយសារបំណុល នៅក្នុងចំណោមក្រុមដែលមានជីវភាពខ្សត់ខ្សោយ បង្កើនការខិតខំអោយមានការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរក្តីព្រហ្មទណ្ឌ និងដំណើរក្តីរដ្ឋប្បវេណី ដោយរួមមានការផ្តល់ការអនុញ្ញាតឲ្យធ្វើការ ស្នាក់នៅបណ្តោះអាសន្ន និងឋានៈស្ថានភាពអន្តោប្រវេសន៍ដទៃទៀតដែលចាំបាច់ ដល់ជនបរទេសជាជនរងគ្រោះ ដែលចង់ស្នាក់នៅក្នុងប្រទេស នៅក្នុងអំឡុងពេលដំណើរការក្តី កែប្រែច្បាប់ដែលអនុញ្ញាតឲ្យមានការផ្តល់សំណងនៅពេលជនល្មើសត្រូវបានដាក់ទោស បង្កើតហើយបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធដែលធ្វើការទាក់ទងនឹងនិតិវិធីការងារជាបទដ្ឋានសំរាប់គណនា  និងផ្តល់សំណង  បង្កើតនីតិវិធីជាប្រព័ន្ធ ហើយកំណត់ធនធានសម្រាប់ជួយជនរងគ្រោះខ្មែរតាមរយៈបេសកកម្មការទូតនៅបរទេស រួមទាំងនៅក្នុងប្រទេសដែលគ្មានតំណាងទូតកម្ពុជា ពង្រឹងការខិតខំក្នុងការត្រួតពិនិត្យក្រុមហ៊ុនជ្រើសរើសកម្លាំងពលកម្មឯកជន និងសាខារបស់គេ ដើម្បីរកមើលការជ្រើសរើសដែលមានលក្ខណៈបន្លំឬការជួញដូរដទៃទៀត បង្កើនការយល់ដឹងរបស់សាធារណជនលើបែបបទដាក់ពាក្យសុំឯកសារធ្វើដំណើរសមស្រប ដើម្បីសម្រួលដល់ការធ្វើចំណាកស្រុកដោយស្របច្បាប់ និងប្រកបដោយសុវត្ថិភាព អនុវត្តប្រព័ន្ធមួយសម្រាប់តាមដាន ប្រមូល និងរាយការណ៍ទិន្នន័យស្តីពីការកាត់ទោសប្រឆាំងការជួញដូរ និងការងារការពារជនរងគ្រោះ  ផ្សព្វផ្សាយទិន្នន័យនៅក្នុងចំណោមស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធ ដើម្បីការពារការសម្ងាត់ឯកជននិងអត្តសញ្ញាណរបស់ជនរងគ្រោះ ពង្រឹងការខិតខំដើម្បីបញ្ចូលគំនិតរបស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងគោលនយោបាយសម្រាប់ផ្ទេរការគ្រប់គ្រងជាផ្លូវការ លើជនរងគ្រោះជាកុមារ បង្កើនការចំណាយធនធានលើនគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បី

សម្រួលដល់ការតាមដានចុងចោទ ដែលត្រូវបានដោះលែងក្រោមការឃ្លាំមើលរបស់តុលាការរហូតដល់មានសវនាការ ។

## ការនាំខ្លួនយកមកកាត់ទោស

រដ្ឋាភិបាលធ្វើការងារពង្រឹងការអនុវត្តច្បាប់មិនគ្រប់គ្រាន់ ហើយអាជ្ញាធរបានខ្វះខ្នាយធនធានក្នុងការកាត់ទោស និងស៊ើបអង្កេត ដោយបែរជាជំរុញការចោទប្រកាន់មិនសមហេតុផល និងមានលក្ខណៈនយោបាយ ប្រឆាំងនឹងឥស្សរជនមកពីគណបក្សប្រឆាំង អ្នកសារព័ត៌មាន និងបុគ្គលដទៃទៀត ដែលចង់ចងក្រងឯកសារស្តីពីការជួញដូរនៅក្នុងប្រទេស។ ច្បាប់ដែលត្រូវបានដាក់ចេញនៅឆ្នាំ ២០០៨ ស្តីពីការបង្ក្រាបការជួញដូរមនុស្ស និងការធ្វើអាជីវកម្មកេងប្រវ័ញ្ចផ្លូវភេទ ដាក់ទោសព្រហ្មទណ្ឌលើការជួញដូរផ្លូវភេទ និងការជួញដូរពលកម្ម ហើយចែងពីការដាក់ទោសជាប់ពន្ធនាគារពី ៧ ដល់ ១៥ ឆ្នាំ បើជនរងគ្រោះជាមនុស្សធំ និងពី ១៥ ទៅ ២០ ឆ្នាំ បើជនរងគ្រោះជាកុមារ។ ទណ្ឌកម្មទាំងនេះមានភាពម៉ឺងម៉ាត់គ្រប់គ្រាន់ ហើយបើទាក់ទងនឹងការជួញដូរផ្លូវភេទ វាស្របតាមទោសសំរាប់បទឧក្រិដ្ឋធ្ងន់ធ្ងរដទៃទៀត ដូចជាការរំលោភសេពសន្ថវៈ។

នគរបាលប្រឆាំងការជួញដូរអនិតិជន (AHTJP) ប្រមូល និងធ្វើកំណត់ហេតុព័ត៌មានស្តីពីករណីដែលខ្លួនបានធ្វើការស៊ើបអង្កេត តែរដ្ឋាភិបាលមិនបានប្រមូលទិន្នន័យពេញលេញស្តីពីការងារពង្រឹងការអនុវត្តច្បាប់ប្រឆាំងនឹងការជួញដូរទេ ពិសេសនៅក្នុងចំណោមតុលាការខេត្ត។ ក្នុងករណីដែលមានទិន្នន័យ ស្ថាប័នរដ្ឋាភិបាលខ្លះ តាមសេចក្តីរាយការណ៍មក មិនចង់ចែកចាយផ្ទៃក្នុង ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗដទៃទៀតជាអន្តរស្ថាប័នទេ។ រដ្ឋាភិបាលបាននិយាយថា អាជ្ញាធរចាប់ខ្លួនមនុស្សក្នុងស្រុក និងជនជាតិបរទេសចំនួន ១៥០ នាក់ ទាក់ទងនឹង "ករណីមិនមែនជួញដូរផ្លូវភេទ" ចំនួន ៣៩ និងករណីជួញដូរផ្លូវភេទចំនួន ២១ (មិនត្រូវបានរាយការណ៍នៅក្នុងឆ្នាំ ២០១៧)។ តុលាការបានកាត់ទោសករណីជួញដូរចំនួន ៤២១ (២០៧ ក្នុងឆ្នាំ ២០១៧) តែអ្នកសង្កេតការណ៍បានកត់សម្គាល់ថា ចំនួនច្បាស់លាស់នៃករណីជួញដូរ នៅក្នុងករណីទាំង ៤២១ នេះគឺទាបជាងនេះច្រើន ដោយសារអាជ្ញាធរមិនបានចែកស្ថិតិឲ្យដាច់ស្រឡះពីគ្នា រវាងការរំលោភសេពសន្ថវៈ និងការជួញដូរ។ ទាក់ទងនឹងការកាត់ទោស

វិញ ស្ថិតិនៃការដាក់ទោសដោយតុលាការគឺនៅមានកម្រិតដោយសារវិធីប្រមូលទិន្នន័យមានលក្ខណៈមិនគ្រប់គ្រាន់។ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គជបជ) បានរាយការណ៍ថាតុលាការក្រុងភ្នំពេញបានដាក់ទោសជនល្មើសចំនួន ១២៥ នាក់ (១២៩ នាក់ នៅឆ្នាំ ២០១៧) រដ្ឋាភិបាលមិនបានផ្តល់ទិន្នន័យស្តីពីការដាក់ទោសដោយតុលាការទេ តែតាមសេចក្តីរាយការណ៍មក តុលាការបានបន្តដាក់ទោសជនសង្ស័យតាមបទចោទមិនសូវធ្ងន់ ហើយបញ្ចប់ករណីជួញដូរផ្លូវភេទដោយការទូទាត់សំណងជាលុយ ជំនួសឲ្យការជាប់ពន្ធនាគារ។ ជនរងគ្រោះដែលគ្រួសាររបស់គេបានទទួលសំណងទូទាត់ក្រៅតុលាការពីជនល្មើស ច្រើនតែប្តូរចម្លើយ ជាកសិណរបស់គេ ដែលជាការធ្វើឲ្យការកាត់ទោសមានភាពកាន់តែស្មុគស្មាញ។

ស្របគ្នាជាមួយនឹងអង្គការមិនមែនរដ្ឋាភិបាល (NGO) មួយ នគរបាលប្រឆាំងការជួញដូរក្រុងព្រះសីហនុបានបណ្តុះបណ្តាលអ្នកតាមសង្កេតធម្មតា ក្នុងចំណោមអ្នករត់តាក់ស៊ី ផ្នែកទេសចរណ៍ ឧស្សាហកម្មបដិសណ្ឋារកិច្ច និងកន្លែងលក់រាយ ដើម្បីតាមដាន និងរាយការណ៍ពីការជួញដូរ។ យ៉ាងណាក្តី អាជ្ញាធរមិនបានរាយការណ៍ថា បានរកឃើញ ឬក៏ផ្តើមធ្វើការស៊ើបអង្កេតទៅលើករណីជួញដូរ ជាលទ្ធផលនៃការខិតខំនេះទេ។ នៅទូទាំងប្រទេស អាជ្ញាធរផ្នែកអនុវត្តច្បាប់មិនបានចាត់វិធានការសមស្របប្រឆាំងនឹងជនសង្ស័យប្រព្រឹត្តការជួញដូរ ឬជនដែលត្រូវបានតុលាការដាក់ទោសហើយ ដោយសារការជួញដូរទេ។ នគរបាលយុត្តិធម៌ខ្វះធនធានសម្រាប់តាមដានចំនួនចុងចោទដែលចេះតែមានចំនួនកើនឡើង ដែលត្រូវបានដោះលែង "ក្រោមការតាមដានរបស់តុលាការ" ដោយរង់ចាំសវនាការ ដែលជាការធ្វើឲ្យពួកគេគេខ្លួនមុនថ្ងៃបើកសវនាការ។ អាជ្ញាធរមិនបានចេញដីកាចាប់ខ្លួនគ្រប់ពេលទេ ដល់ចុងចោទដែលរត់គេចខ្លួនទេ។ ដោយនិយាយថា ខ្វះធនធាន ព្រះរាជអាជ្ញា និងចៅក្រមស៊ើបអង្កេតមិនបានពិចារណាចាត់ការលើករណីជួញដូរ ដែលនគរបាលបានផ្តល់ភស្តុតាងឲ្យហើយនោះទេ។ អាជ្ញាធរបានប្រើដោយខុស នូវធនធានសម្រាប់ផ្នែកអនុវត្តច្បាប់ ដើម្បីឃុំខ្លួន កាត់ទោស និងដាក់ទោសបុគ្គលខ្លះ តាមការចោទពីបទជួញដូរដែលឈរលើហេតុផលនយោបាយ។ ការនេះរឹតតែធ្វើឲ្យគេមានការសង្ស័យលើភាពត្រឹមត្រូវនៃទិន្នន័យប្រឆាំងការជួញដូរ និងកង្វះធនធាន ដូចដែលរដ្ឋាភិបាលបាននិយាយមក។ អ្នកសារព័ត៌មាន ២ នាក់ដែលធ្វើការឲ្យផ្នែកសារព័ត៌មានបរទេស និងអតីតបេក្ខជនសមាជិកសភាម្នាក់ ដែលមកពីគណបក្ស

ប្រឆាំងដែលត្រូវបានហាមប្រាមទាំងអយុត្តិធម៌ បន្តស្ថិតនៅក្រោមការឃុំខ្លួននៅឡើយ ក្រោមការចោទប្រកាន់ដោយមិនត្រឹមត្រូវថា បានធ្វើការជួញដូរមនុស្ស គិតមកដល់ដំណាច់នៃអំឡុងពេលនៃការធ្វើរបាយការណ៍នេះ។ អាជ្ញាធរថៃមទាំងបានធ្វើការចោទប្រកាន់ព្រហ្មទណ្ឌដោយមិនសមហេតុផលប្រឆាំងនឹងជនស៊ីវិល ដែលចង់ចងក្រងឯកសារស្តីពីបញ្ហាប្រឈមនៃការជួញដូរមនុស្ស នៅកម្ពុជា។ នៅខែធ្នូ អាជ្ញាធរបានធ្វើបត្យាប័នប្រកបដោយជោគជ័យ នៃជនជាតិខ្មែរម្នាក់ដែលផលិតឯកសារ ពីប្រទេសថៃ ហើយបានចោទប្រកាន់គាត់ពីបទ "ធ្វើការញុះញង់" ដោយសារគាត់បានជួយសារព័ត៌មានបរទេសមួយ ក្នុងការផលិតភាពយន្តមួយ ស្តីពីជនរងគ្រោះម្នាក់ដោយសារការជួញដូរ នៅកម្ពុជា។ នៅដំណាច់រយៈពេលធ្វើរបាយការណ៍នេះ គាត់ស្ថិតនៅក្នុងការឃុំឃាំងមុនសវនាការនៅឡើយ ហើយអាជ្ញាធរសម្រេចមិនធ្វើការស៊ើបអង្កេតលើករណីដែលគាត់ចង់បង្ហាញ តាមរយៈភាពនយន្តឯកសារនោះទេ។ អ្នកជំនាញនៅក្នុងប្រទេសបានបន្តនិយាយថា ករណីទាក់ទងនឹងជនសង្ស័យជាបរទេសច្រើននាំដល់ការដាក់ទោសដោយតុលាការច្រើនជាងករណីជនសង្ស័យជាខ្មែរ ដែលច្រើនតែទទួលបានការបន្ថយការចោទប្រកាន់មកត្រឹមបទល្មើសមិនសូវធ្ងន់ធ្ងរទៅវិញ។

រដ្ឋាភិបាលមានចុះអនុស្សារណៈនៃកិច្ចព្រមព្រៀង ដោយមានគូសបញ្ជាក់ពីការស៊ើបអង្កេតប្រឆាំងការជួញដូរមនុស្សឆ្លងដែន ជាមួយប្រទេសថៃ និងវៀតណាម ព្រមទាំងសន្ធិសញ្ញាធ្វើបត្យាប័នជាមួយប្រទេសថៃ តែមិនបានរាយការណ៍ពីការស៊ើបអង្កេតឬធ្វើបត្យាប័នជនល្មើសសង្ស័យណាមួយទេ នៅក្រោមការគ្រប់គ្រងរបស់គេ នៅឆ្នាំ ២០១៨។ អាជ្ញាធរបានបន្តធ្វើការបណ្តុះបណ្តាលតាមការរៀបចំ និងក្រោមថវិការបស់ម្ចាស់ជំនួយ ស្តីពីការអនុវត្តច្បាប់ប្រឆាំងការជួញដូរ ដល់នគរបាល ព្រះរាជអាជ្ញា ចៅក្រម និងមន្ត្រីដទៃទៀតនៃរដ្ឋាភិបាល។

នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ គជបជ បានបើកការបណ្តុះបណ្តាលចំនួន ២៣៤ ដល់មន្ត្រីសមត្ថកិច្ចចំនួន ៦ ៣២១ នាក់ ស្តីពីច្បាប់ប្រឆាំងការជួញដូរមនុស្ស បច្ចេកទេសស៊ើបអង្កេត និងការប្រមូលភស្តុតាង (មានការបណ្តុះបណ្តាលចំនួន ៦៦ ដល់មន្ត្រីចំនួន ១៥៧៧ នាក់ នៅក្នុងឆ្នាំ ២០១៧)

។ នៅឆ្នាំទី ២ គជបជ មិនបានប្រាប់ថា តើមន្ត្រីថ្នាក់ខេត្តនិងឃុំ បុគ្គលិកតុលាការ និងអ្នកធ្វើការក្នុងអង្គការ NGO ប៉ុន្មាននាក់ដែលបានចូលរួមនៅក្នុងវគ្គសិក្សាទាំងនេះ (មាន ៧៦៨៩ នាក់ នៅឆ្នាំ ២០១៦)។ ទោះបីជាបានទទួលការបណ្តុះបណ្តាលទាំងនេះក្តី តែមាននគរបាលជាច្រើន ពិសេសនគរបាលនៅតាមជនបទ មិនដឹងពីរបៀបធ្វើការងារប្រឆាំងការជួញដូរទេ ដោយសារភាគច្រើននៃពួកគេមិនបានទទួលការបណ្តុះបណ្តាលស្តីពីបច្ចេកទេសពង្រឹងការអនុវត្តច្បាប់ជាមូលដ្ឋាន។ អង្គការក្នុងស្រុក និងមន្ត្រីខ្លះមើលឃើញសេចក្តីត្រូវការជាបន្ទាន់លើបច្ចេកទេសប្រមូលភស្តុតាងទំនើប ដែលរួមមានការស៊ើបអង្កេតជាសម្ងាត់ ការបន្ថយការពឹងផ្អែកលើការឆ្លើយរបស់សាក្សី ហើយបង្កើនការខិតខំក្នុងការតាមដាន និងប្រយុទ្ធប្រឆាំងនឹងការជួញដូរផ្លូវភេទ។ យ៉ាងណាក្តី រដ្ឋាភិបាលមិនបានផ្តល់អំណាចក្នុងការធ្វើការស៊ើបអង្កេតដោយសម្ងាត់ ដល់អង្គភាពនគរបាលប្រឆាំងការជួញដូរមនុស្សទេ លើកលែងករណីកម្រដែលមានការស្នើសុំឲ្យមានការធ្មក់ឆែកឆេរទាក់ទងនឹងទេសចរណ៍ផ្លូវភេទលើកុមារ ដែលត្រូវបានធ្វើជាមួយសមត្ថកិច្ចបរទេស។ ការនេះរាំងស្ទះខ្លាំងដល់សមត្ថភាពរបស់មន្ត្រីអនុវត្តច្បាប់ក្នុងការដោះស្រាយចំពោះលក្ខណៈកាន់តែមានភាពសម្ងាត់ឡើង នៃការជួញដូរផ្លូវភេទ នៅកម្ពុជា។ ស្ថាប័នរដ្ឋាភិបាលដែលចង់ធ្វើឲ្យមានជាផ្លូវការឡើងនូវអាជ្ញាធរស៊ើបអង្កេតជាសម្ងាត់ បានបន្តការចរចាផ្លូវការ ជាមួយស្ថាប័នប្រឆាំង ស្តីពីកំណែទម្រង់ដែលអាចធ្វើទៅបាន តែគេមិនបានឈានដល់កិច្ចព្រមព្រៀងទេ ហើយអ្នកសង្កេតការណ៍ខ្លះបានចោទសួរពីប្រសិទ្ធភាពនៃដំណើរការពិគ្រោះយោបល់ទូលំទូលាយ។

អំពើពុករលួយដែលមានជាទូទៅនៅគ្រប់លំដាប់ថ្នាក់ទាំងអស់ក្នុងរដ្ឋាភិបាលកម្ពុជា រឹតត្បិតយ៉ាងខ្លាំងលើលទ្ធភាពរបស់មន្ត្រីម្នាក់ៗ ក្នុងការចាប់ជនប្រព្រឹត្តការជួញដូរទទួលខុសត្រូវ។ នគរបាលជាតិកម្ពុជាមាន យន្តការមួយឲ្យអ្នកធ្វើការក្នុងអង្គការ NGO រាយការណ៍ពីករណីពុករលួយរបស់នគរបាលប្រឆាំងការជួញដូរ តែមិនបានប្តឹងទេ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ មន្ត្រីមូលដ្ឋានបានជួយសម្រួលការជួញដូរមនុស្សឆ្លងកាត់ព្រំដែន ដោយទទួលយកសំណូកជាថ្នូរនឹងការបន្លំឯកសារអត្តសញ្ញាណបណ្ណ។ អង្គការ NGO មួយបានកត់សម្គាល់ឃើញថា ការធ្មក់ឆែកឆេរដោយសមត្ថកិច្ចនៅតាមកន្លែងជួញដូរផ្លូវភេទ ពេលខ្លះ មិនបានទទួលជោគជ័យទេ ដោយសារមានការប្រាប់ឲ្យដឹងជាមុន ដោយនគរបាលដែលចូលរួមធ្វើការងារនោះ។ តែថ្នាក់ដឹកនាំនគរបាលខេត្តខ្លះត្រូវបានរាយការណ៍មកថា បានមានវិធានការ

ដើម្បីកាត់បន្ថយការធ្លាយព័ត៌មានសម្ងាត់នេះ ដោយប្រគល់ករណីនេះទៅឲ្យ AHTJP ដែលធ្វើការធ្មក់ផែកធេរដោយឯករាជ្យ ដោយមិនប្រាប់អាជ្ញាធរមូលដ្ឋានទេ រហូតដល់ជិតចាប់ផ្ដើមធ្វើ។ មន្ត្រីពុករលួយខ្លះអាចទទួលប្រយោជន៍ដោយផ្ទាល់ពីកន្លែងដែលត្រូវបានសង្ស័យថា ធ្វើការជួញដូរផ្លូវភេទ និងជួញដូរកំលាំងពលកម្ម។ អ្នកសង្កេតការណ៍មកពីអង្គការ NGO បានអះអាងថា មន្ត្រីនគរបាលកម្ពុជាខ្លះក៏មានការរួមភេទជាលក្ខណៈជួញដូរជាមួយអនិតិជនដែរ នៅក្នុងរយៈកាលនៃរបាយការណ៍នេះ។ មាន NGO មួយបាននិយាយថា ព្រះរាជអាជ្ញា និងចៅក្រមបានទទួលសំណូកជាថ្នូរនឹងការទម្លាក់ចោលបទចោទប្រកាន់ និងចេញសាលក្រមថា គ្មានទោស។ មន្ត្រីពុករលួយច្រើនតែបង្អាក់ដំណើរជឿនលឿន នៅក្នុងករណីដែលជនប្រព្រឹត្តត្រូវបានគេជឿថា មានទំនាក់ទំនងនយោបាយ ព្រហ្មទណ្ឌ ឬសេដ្ឋកិច្ច ជាមួយមន្ត្រីរដ្ឋាភិបាល។ ទោះបីជាមាននិន្នាការទាំងនេះក្ដី រដ្ឋាភិបាលមិនបានស៊ើបអង្កេត នាំយកមកកាត់ទោស ឬដាក់ទោសបុគ្គលិករដ្ឋណាមួយដែលសមគំនិតក្នុងការជួញដូរ ឬចាត់វិធានការដាក់ទណ្ឌកម្មណាមួយប្រឆាំងនឹងអតីតមេនគរបាលប្រឆាំងការជួញដូរមនុស្សរាជធានីភ្នំពេញ ដែលត្រូវបានដំឡើងសក្តិ បន្ទាប់ពីការដាក់ទោសនៅឆ្នាំ ២០១១ ទៅលើគាត់ពីបទជួញដូរមនុស្ស ត្រូវបានលុបចោលទៅវិញ នៅក្នុងសវនាការបិទទ្វារ និងដោយគ្មានការប្រកាសរបស់តុលាការកំពូល នៅឆ្នាំ ២០១៣។

## ការការពារ (Protection)

រដ្ឋាភិបាលបានបន្ថយការខិតខំក្នុងការងារការពារ។ ទោះបីជាមានគោលការណ៍ណែនាំក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ ដែលធ្វើដោយក្រសួងសង្គមកិច្ច នៅដើមឆ្នាំ ២០១៧ ក្ដី តែការបញ្ជូន និងការកំណត់អត្តសញ្ញាណ និងការធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះនៅតែមិនស៊ីចង្វាក់គ្នា ហើយនៅខ្សោយ នៅក្នុងស្ថាប័នសមត្ថកិច្ច ទាំងមូល។ អាជ្ញាធរមិនបានផ្ដល់ស្ថិតិពេញលេញស្ដីពីចំនួនជនរងគ្រោះដែលខ្លួនបានជួយ ឬបញ្ជូនទេ។ រដ្ឋាភិបាលមិនបានបន្តអនុវត្តបទបញ្ជាដែលរារាំងមិនអោយអង្គការមិនមែនរដ្ឋាភិបាលធ្វើជាតំណាងអោយបុគ្គលដែលស្វែងរកការទទួលស្គាល់ជាផ្លូវការថា ជាជនរងគ្រោះ។ តាមរយៈវិធីនេះ ដែល NGO អះអាងថា បានគំរាមកំហែងយ៉ាងខ្លាំងដល់ជនរងគ្រោះ និងគ្រួសាររបស់គេ ជនរងគ្រោះត្រូវបានគេតម្រូវឲ្យទាក់ទងទៅក្រសួងមហាផ្ទៃ ដើម្បីសុំការកំណត់អត្តសញ្ញាជាផ្លូវការ ដើម្បីអាច

ទទួលបានសេវាការពារ។ ដោយមានជំនួយពីអង្គការអន្តរជាតិមួយ រដ្ឋាភិបាលបានដំណើរការមណ្ឌលសំចតបណ្តោះអាសន្នពីរ នៅទីក្រុងព្រំដែនប៉ោយប៉ែត ដែលនៅទីនោះ គេរកមើលជនរងគ្រោះដោយការជួញដូរ នៅក្នុងចំណោមអ្នកធ្វើចំណាកស្រុកចំនួនប្រហែល ៧០ ២២៥ នាក់ ដែលត្រូវបានចាប់បញ្ជូនមកពីប្រទេសថៃ នៅឆ្នាំ ២០១៧ ……. ។ តែអាជ្ញាធរមិនបានរាយការណ៍ពីការរកឃើញជនរងគ្រោះណាម្នាក់ តាមរយៈមជ្ឈមណ្ឌលនេះទេ ទោះបីជាក្នុងចំណោមមនុស្សទាំងនោះ អាចមានភាពរងគ្រោះដោយការជួញដូរមនុស្សក្តី ហើយកង្វះការអនុវត្តជាទូទៅ នូវបទដ្ឋានកំណត់អត្តសញ្ញាណជនរងគ្រោះ នាំអោយជនរងគ្រោះជាច្រើនបានឆ្លងផុតមជ្ឈមណ្ឌលនេះដោយមិនត្រូវបានគេដឹងទេ។

រដ្ឋាភិបាលបានដំណើរការមជ្ឈមណ្ឌលសំចតបណ្តោះអាសន្នមួយ នៅភ្នំពេញ សំរាប់ទទួលជនរងគ្រោះដោយការជួញដូរនិងបទល្មើសជទៃទៀតជាស្ត្រី  ហើយបានបញ្ជូនជនរងគ្រោះដោយការជួញដូរទៅជម្រករបស់អង្គការមិនមែនរដ្ឋាភិបាល ដែលទទួលបានការឧបត្ថម្ភថវិកាពីម្ចាស់ជំនួយ ដោយភាគច្រើនទទួលយកជនរងគ្រោះដោយការធ្វើបាបក្នុងទម្រង់ជាច្រើន  ដើម្បីអោយទទួលការជួយបន្ថែមទៀត។ គេនិយាយថា សង្គមកិច្ចមានគោលការណ៍ណែនាំដែលមាននិយាយពីបទដ្ឋានអប្បបរមា សម្រាប់ការថែទាំនៅតាមផ្ទះ នូវជនរងគ្រោះដោយការជួញដូរ ហើយបានផ្សព្វផ្សាយគោលការណ៍ណែនាំទាំងនោះ នៅក្នុងចំណោមទីជម្រករបស់ NGO នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ រដ្ឋាភិបាលបានបន្តពឹងផ្អែកខ្លាំងលើ NGO នៅក្នុងការការពារជនរងគ្រោះ តែរដ្ឋាភិបាលមិនជួយសម្រួលដល់ការផ្ទេរជាផ្លូវការ នៃការគ្រប់គ្រងលើជនរងគ្រោះជាកុមារទេ ដែលជាការធ្វើអោយអង្គការដែលទទួលជនរងគ្រោះជាកុមារ អាចរងបណ្តឹងតុលាការ។ គេនិយាយថា បញ្ហាដែលនៅតែមាន ទាក់ទងនឹងការគ្រប់គ្រងជនរងគ្រោះ ធ្វើអោយទីជម្រករបស់ NGO ខ្លះមិនចង់ការពារសេរីភាពក្នុងការដើរហើររបស់អ្នកនៅក្នុងនោះ ដែលជាការផ្ទុយនឹងទំលាប់ល្អដែលត្រូវធ្វើ។ ថ្វីបើ NGO ដែលធ្វើការប្រឆាំងការជួញដូរខ្លះ ទទួលបានការធ្វើសហប្រតិបត្តិការពីអាជ្ញាធរក្តី ដោយរួមមានតាមរយៈការទទួលបាននូវការគាំទ្រជាសម្ភារៈ តែការរឹតត្បិតកាន់តែច្រើនលើសង្គមស៊ីវិលបានរារាំងការងារនៃ NGO សំខាន់ៗ ដែលធ្វើការប្រឆាំងការជួញដូរ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ។ បញ្ញត្តិដែលអនុញ្ញាតឲ្យមានការសងសំណងជាលុយ ជំនួសអោយការដាក់ពន្ធនាគារដែលមានលក្ខណៈធ្ងន់ធ្ងរជាងនេះ កាន់តែធ្វើឲ្យគ្រួសារខ្លះមិនសូវចង់បញ្ជូនជនរងគ្រោះទៅមណ្ឌលសំចត

បណ្តោះអាសន្ន ហើយដោយគ្មានការយល់ព្រមពីគ្រួសារ ពេលខ្លះ មន្ត្រីរដ្ឋាភិបាលបញ្ជូនកុមារអោយទៅនៅក្នុងបរិយាកាសដែលមានការប្រឈមខ្លាំង ដែលជាការនាំឲ្យកុមារទាំងនោះងាយរងនឹងការធ្លាក់ខ្លួនជាជនរងគ្រោះម្តងទៀត។ ថ្វីបើជនរងគ្រោះដោយសារការជួញដូរកម្លាំងពលកម្មមានច្រើននៅក្នុងចំណោមបុរសក្តី តែជំនួយដែលត្រូវបានផ្តល់សំរាប់ជនរងគ្រោះទាំងនោះ នៅមានកំរិតនៅឡើយ។

ស្ថានបេសកកម្មទូតនៅបរទេសនៅតែខ្វះថវិកាឬសមត្ថភាពគ្រប់គ្រាន់ ក្នុងការផ្តល់ជំនួយចាំបាច់ ឬបញ្ជូនជនរងគ្រោះមកមាតុភូមិវិញ ថ្វីបើរដ្ឋាភិបាលបានចេញវិធានការក្នុងឆ្នាំមុនៗ ក្នុងការបណ្តុះបណ្តាលអ្នកការទូតស្តីពីការការពារពលករចំណាកស្រុកក្តី។ ជនរងគ្រោះដែលត្រូវបានរកឃើញនៅក្នុងប្រទេសដែលគ្មានតំណាងទូតកម្ពុជា រឹតតែមិនសូវទទួលបានការជួយទៅទៀត។ ការសិក្សាមួយដែលត្រូវបានធ្វើដោយអង្គការអន្តរជាតិមួយ នៅក្នុងអំឡុងពេលនៃរបាយការណ៍លើកមុន បានរកឃើញថា មានពលករចំណាកស្រុកចំនួនតែ ២១% តែប៉ុណ្ណោះដែលបានស្វែងរកជំនួយចំពោះការរំលោភធ្វើបាបនៅបរទេស ដោយរួមមានទាំងការបង្ខំអោយធ្វើការ។ ក្រសួងការបរទេសដែលមាននាទីចម្បង ក្នុងការជួយជនរងគ្រោះខ្មែរដោយការជួញដូរ បាននិយាយថា ខ្លួនបានជួយដោយមានកម្រិត និងធ្វើមាតុភូមិនិវត្តន៍ជនជាតិខ្មែរចំនួន ៨៤៨៩នាក់ ពីប្រទេសចំនួន ៦ ដោយរួមមានស្ត្រីចំនួន ៣៣០ នាក់ពីប្រទេសថៃ ចិន ម៉ាឡេស៊ី ឥណ្ឌូនេស៊ី អារ៉ាប៊ីសាអ៊ូឌីត និងសូម៉ាលី។ តែមិនដូចអំឡុងពេលនៃការធ្វើរបាយការណ៍លើកមុនទេ អាជ្ញាធរមិនបានបញ្ជាក់ថា តើក្នុងចំណោមអ្នកទាំងនោះ មានប៉ុន្មាននាក់ជាជនរងគ្រោះដោយការជួញដូរ (៩៨៦ នៅឆ្នាំ ២០១៧)។ ភាគច្រើននៃពួកគេត្រូវបានបញ្ជូនមកមាតុភូមិវិញ ក្រោមជំនួយរបស់អង្គការអន្តរជាតិមួយ។ អ្នកសង្កេតការណ៍ជឿថា តួលេខនេះគឺគ្រាន់តែជាចំណែកតូចមួយនៃចំនួនប្រជាជនកម្ពុជាដែលរងគ្រោះដោយការជួញដូរនៅបរទេស ពិសេសនៅក្នុងផ្នែកនេសាទ។ ក្រសួងការបរទេសមិនបានប្រកាសឲ្យប្រើឬអនុវត្តនីតិវិធីប្រតិបត្តិជាបទដ្ឋានក្នុងការរក និងបញ្ជូនជនរងគ្រោះខ្មែរនៅបរទេសទេ ដែលធ្វើឲ្យជនជាតិខ្មែរជាច្រើនគ្មានបានទទួលការជួយចាំបាច់ ដើម្បីធ្វើមាតុភូមិនិវត្តន៍ ដោយស្របច្បាប់ និងដោយសុវត្ថិភាពទេ។ យោងតាមអង្គការ NGO ជនរងគ្រោះដែលត្រូវបានបញ្ជូនត្រឡប់វិញ មិនអាចទទួលបានជំនួយពីផ្នែកកុងស៊ុលរបស់កម្ពុជាប្រចាំនៅប្រទេសចិន កូរ៉េ និងថៃទេ ដោយសារទូរស័ព្ទខ្សែ Hotline គ្មានអ្នកនៅប្រចាំការ និងបុគ្គលិកគ្មានការឆ្លើយតប ។ អ្នកខ្លះ ដែលត្រូវជាប់ក្នុងស្ថានភាពបង្ខំឲ្យធ្វើពល

កម្មនៅបរទេស ដូចជានៅប្រទេសម៉ាឡេស៊ី មិនអាចឲ្យបុគ្គលិកផ្នែកកុងស៊ុលកម្ពុជាជឿថា ពួកគេត្រូវការជំនួយទេ។ ប្រទេសកម្ពុជាមានអនុព័ន្ធការងារនៅតាមស្ថានទូតនៅប្រទេសកូរ៉េ ម៉ាឡេស៊ី និងថៃ ដែលសុទ្ធតែជាប្រទេសដែលមានចំនួនពលករចំណាកស្រុកកម្ពុជាច្រើនជាងគេ តែមិនបានផ្តល់ទិន្នន័យស្តីពីការចូលរួមរបស់ខ្លួននៅក្នុងការរកមើល ឬជួយជនរងគ្រោះដោយសារការជួញដូរពលកម្មទេ។

ចំនួនអ្នកវិលត្រឡប់វិញ ដែលបានរងការជួញដូរនៅបរទេស ទំនងជាមានច្រើនជាងចំនួនក្នុងសេចក្តីរាយការណ៍ ដោយសារក្រុមទាំងនេះច្រើនតែវិលមកវិញក្នុងលក្ខណៈក្រៅផ្លូវការ ហើយនិងដោយសារខ្វះនិតិវិធីក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះ។ ក្រសួងសង្គមកិច្ចបានរាយការណ៍ថាបានជួយធ្វើមាតុភូមិនិវត្តន៍ជនជាតិខ្មែរចំនួន ២២២ នាក់ ដែលត្រូវបានរកឃើញដោយ NGO និងរដ្ឋាភិបាលបរទេសនៅឆ្នាំ ២០១៨ ដែលក្នុងនោះ មាន ៦១ នាក់មកពីប្រទេសម៉ាឡេស៊ី ២០ នាក់ពីប្រទេសថៃ ៨៩ នាក់ពីប្រទេសចិន ២១ នាក់ពីប្រទេសសូម៉ាលី ២៩ នាក់ពីប្រទេសវៀតណាម និង ២ នាក់ពីប្រទេសអារ៉ាប៊ីសាអ៊ូឌីត (នៅឆ្នាំ ២០១៧ មានសរុបចំនួន ២៤៣ នាក់)។ ក្នុងចំណោមអ្នកទាំងនេះ មាន ១០៩ នាក់រងគ្រោះដោយការបង្ខំឲ្យធ្វើពលកម្ម។ បើយោងតាមក្រសួងសង្គមកិច្ច មាន ៩៦ នាក់មានការទាក់ទងនឹងការរៀបការដោយបង្ខំ ឬដោយបោកបញ្ឆោត ហើយអាជ្ញាធរមិនបាននិយាយថា តើករណីទាំងនេះជាការជួញដូរផ្លូវភេទ ឬជាការបង្ខំធ្វើពលកម្ម។ អ្នកឯទៀតគឺជាជនរងគ្រោះដោយការជួញដូរផ្លូវភេទ។ ក្រសួងសង្គមកិច្ច បាននិយាយថា បានបញ្ជូនមនុស្សទាំង ២២២ នាក់ទៅNGO (មិនត្រូវបាននិយាយទេ នៅក្នុងឆ្នាំ ២០១៧ ហើយបានបញ្ជូនចំនួន ៦២ នាក់ដោយក្រសួងសង្គមកិច្ច នៅឆ្នាំ ២០១៦)។ ក្រសួងសង្គមកិច្ចក៏បានរាយការណ៍ផងដែរថាបានជួយក្នុងការធ្វើសមាហរណកម្មជនរងគ្រោះដោយការការជួញដូរកម្ពុជាចំនួន ៣០៣ នាក់ ហើយបានបញ្ជូនមនុស្សចំនួន ៨៤៨ នាក់បន្ថែមទៀតទៅឲ្យ NGO គ្រប់គ្រង។ ករណីខ្លះនៃករណីទាំងនេះប្រហែលត្រូវបានរកឃើញ នៅឆ្នាំមុន ហើយគេប្រហែលជាបញ្ចូលជនរងគ្រោះទាំងនេះទៅក្នុងទម្រង់ផ្សេងទៀតនៃការធ្វើបាប។ នគរបាលមូលដ្ឋានបានបញ្ជូនជនរងគ្រោះដោយការជួញដូរផ្លូវភេទ និងជួញដូរពលកម្មចំនួន ២៣៥ នាក់ ទៅផ្នែកសង្គមកិច្ចខេត្ត និង NGO ដើម្បីឲ្យផ្តល់ការការពារបន្ថែម (១៧៩ នាក់ នៅឆ្នាំ ២០១៧ និង ៣២៦ នាក់ នៅឆ្នាំ ២០១៦)។ NGO មួយបានផ្តល់ជំនួយដល់ជនជាតិខ្មែរចំនួន ១៨០ នាក់ ដែលរងការជួញដូរផ្លូវភេទ ការបង្ខំអោយធ្វើពលកម្ម ឬស្ថានភាពបែបនេះ

នៅក្នុងផ្នែកនេសាទ និងការរំលោភធ្វើបាបដែលមានលក្ខណៈស្មើនឹងការជួញដូរ ទាក់ទងនឹងការរៀបការដោយបង្ខំ ឬដោយក្លែងបន្លំ។

គ្មានបញ្ញត្តិសម្រាប់ផ្តល់ការអនុញ្ញាតឲ្យធ្វើការ ការស្នាក់នៅបណ្តោះអាសន្ន ឬក៏ឋានៈជាជនអន្តោប្រវេសន៍ដទៃទៀតណាឡើយ ដល់ជនរងគ្រោះជាជនបរទេស ដែលចង់ស្នាក់នៅក្នុងប្រទេសកម្ពុជា ដើម្បីចូលរួមនៅក្នុងនីតិវិធីព្រហ្មទណ្ឌ ឬនីតិវិធីរដ្ឋប្បវេណីទេ។ រដ្ឋាភិបាលតម្រូវឲ្យធ្វើមាតុភូមិនិវត្តន៍នៃជនរងគ្រោះបរទេស លើកលែងក្នុងករណីកម្រ ហើយមិនបានផ្តល់ជម្រើសផ្សេងផ្នែកច្បាប់ដល់ការបញ្ជូនពួកគេទេ ទោះបីជាគេប្រឈមនឹងភាពពិបាក ឬការសងសឹក នៅពេលគេទៅដល់ប្រទេសកំណើតរបស់គេវិញក៏ដោយ។ ក្រសួងសង្គមកិច្ចមិនបានបញ្ជូនជនរងគ្រោះជាបរទេស ដោយការជួញដូរឲ្យធ្វើទៅប្រទេសគេវិញទេ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ (ជនរងគ្រោះ ២ នាក់ជាជនជាតិវៀតណាមត្រូវបានធ្វើមាតុភូមិនិវត្ត នៅដើមឆ្នាំ ២០១៨ ៣ នាក់នៅឆ្នាំ ២០១៧ និង ១៣ នាក់ នៅឆ្នាំ ២០១៦)។ ការមិនសូវមានការខិតខំក្នុងការកំណត់អត្តសញ្ញាណជនរងគ្រោះបានធ្វើឲ្យមនុស្សជាច្រើនដែលអាចជាជនរងគ្រោះដោយការជួញដូរ ប្រឈមមុខនឹងទណ្ឌកម្មរបស់សមត្ថកិច្ចទៅវិញ ដោយរួមមានទាំងការចាប់បញ្ជូនត្រឡប់ទៅប្រទេសកំណើតវិញ ដោយគ្មានការត្រួតពិនិត្យជាមុន។ សមត្ថកិច្ចច្រើនតែមិនដាក់ជនរងគ្រោះនិងជនល្មើសនៅដាច់ពីគ្នាក្នុងពេលសម្ភាស។ NGO បានកត់សម្គាល់ឃើញថា នគរបាលមានភាពជឿនលឿនខ្លះ នៅក្នុងការងារអនុវត្តដែលមានលក្ខណៈល្អចំពោះកុមារ នៅក្នុងអំឡុងពេលនៃរបាយការណ៍នេះ ហើយអ្នកធ្វើការផ្នែកសង្គមកិច្ចរបស់រដ្ឋាភិបាលបានរាយការណ៍ពីការធ្វើសហប្រតិបត្តិការជាមួយ AHTJP ដែលរួមមានការយកជនរងគ្រោះបានទាន់ពេល និងនីតិវិធីនៃការបញ្ជូន។ តែ តុលាការថ្នាក់ខេត្តមិនបានអនុវត្តជាទូទៅ នូវកម្មវិធីដែលត្រូវបានផ្តើមឡើងនៅឆ្នាំ ២០១៦ ទាក់ទងនឹងក្តីក្តាំក្នុងតុលាការដែលជាជម្រើសល្អសម្រាប់កុមារទេ  ដើម្បីសម្រួលដល់ការធ្វើកសិណដោយកុមារ ដោយរួមមានការមិនឲ្យសួរកុមារក្នុងតុលាការនៅចំពោះមុខជនជាប់ចោទ ហើយបែរមកប្រើបច្ចេកទេសសួរពីចំងាយតាមរយៈទូរស័ព្ទដោយមានឲ្យឃើញរូបវិញ។ ប្រព័ន្ធច្បាប់ពុករលួយនិងខ្សោយរបស់ប្រទេសកម្ពុជា ហើយនិងកង្វះការការពារគ្រប់គ្រាន់សំរាប់ជនរងគ្រោះ និងសាក្សី ដែលត្រូវបានធ្វើអោយកាន់តែអាក្រក់ឡើងដោយដំណើរការកាត់ក្តីយូរ និងការភ័យខ្លាចការសងសឹកដោយជនប្រព្រឹត្តការជួញដូរ បង្កជាឧបសគ្គដល់ជនរងគ្រោះ

មិនឲ្យមានចិត្តចង់ធ្វើសហប្រតិបត្តិការនៅក្នុងករណីជាច្រើន។ ជាគោលការណ៍ ជនរងគ្រោះអាចទទួលបានសំណងទូទាត់ តែការនេះមានការពិបាកដោយលក្ខខណ្ឌផ្លូវច្បាប់ដែលចែងថា ការទូទាត់សងអាចត្រូវបង់ឲ្យតែនៅពេលជនល្មើសចេញពីពន្ធនាគារវិញតែប៉ុណ្ណោះ។ ការគេចខ្លួនជាញឹកញាប់របស់ជនល្មើសដែលតុលាការបានដាក់ទោសហើយនោះ ធ្វើឲ្យរឿងនេះរឹតតែមានភាពស្មុគស្មាញកាន់តែច្រើន។ អ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញថា ប្រទេសកម្ពុជាខ្វះនីតិវិធីប្រតិបត្តិតាមលក្ខណៈបទដ្ឋាន ចំពោះគណនាសំណង។ ជនរងគ្រោះកម្រទទួលបានទឹកប្រាក់ក្នុងចំនួនដែលបានសន្យាណាស់ ហើយគ្រួសារជនរងគ្រោះជាច្រើនដោះស្រាយក្រៅតុលាការ ជាមួយជនល្មើស ឬទទួលយកសំណូកជាថ្នូរនឹងការទម្លាក់ចោលការចោទប្រកាន់។

## ការការពារជាមុន

(Prevention)

រដ្ឋាភិបាលកម្ពុជាបានបន្តការងារការការពារជាមុន កុំឲ្យមានការជួញដូរមនុស្ស។ គណៈកម្មាធិការអន្តរក្រសួង និងលេខាធិការដ្ឋានរបស់គណៈកម្មាធិការនេះ បានសម្របសម្រួលសកម្មភាពប្រឆាំងការជួញដូរ ហើយបានផ្តួចផ្តើមពង្រាងផែនការសកម្មជាតិជាតិ ឆ្នាំ ២០១៩ - ២០២៣ តែមកទល់នឹងដំណាច់រយៈពេលនៃរបាយការណ៍នេះ រដ្ឋាភិបាលមិនបានផ្តល់ការយល់ព្រមលើផែនការនេះទេ។ រដ្ឋាភិបាលបានបន្តធ្វើប្រតិបត្តិការក្រោមថវិកាចំនួន ៤,៩ ពាន់លានរៀល (១,១៩ លានដុល្លា)ដែលត្រូវបានកំណត់បែងចែកនៅក្នុងអំឡុងពេលនៃការធ្វើរបាយការណ៍លើកមុន សម្រាប់គណៈកម្មាធិការអន្តរក្រសួងនេះ តែអ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញថា តួលេខនេះនៅមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ គណៈកម្មាធិការប្រឆាំងការជួញដូរសាខាថ្នាក់ខេត្ត ដែលតាមសេចក្តីរាយការណ៍មក បានបន្តទទួលបានថវិកាមិនច្រើនពីរដ្ឋាភិបាល និងបានទទួលជំនួយពី NGO បានធ្វើការសម្របសម្រួលការងារនៅថ្នាក់មូលដ្ឋាន ស្របតាមផែនការសកម្មភាពជាតិ។ ដោយមានជំនួយពីម្ចាស់ជំនួយអន្តរជាតិ ៨ ក្នុងចំណោម៩ នៃគណកម្មាធិការទាំងនេះបានបង្កើតផែនការសកម្មភាពថ្នាក់ខេត្តរបស់គេផ្ទាល់ ហើយដាក់ស្នើទៅរដ្ឋាភិបាល (៦ នៅឆ្នាំ ២០១៧ និង ៥ នៅឆ្នាំ ២០១៦)។ លេខាធិការដ្ឋាននៃ NCCT មានក្រុមការងារមួយតាមមើលការងារ

របស់គណៈកម្មាធិការអន្តរក្រសួង ព្រមទាំងការងាររបស់អនុគណៈកម្មាធិការខេត្តរបស់ខ្លួន។ ថវិកាសម្រាប់ការងារទប់ស្កាត់ការជួញដូរ នៅថ្នាក់ឃុំ មានការកើនឡើងនៅក្នុងអំឡុងពេលនៃរបាយការណ៍ តែ NGO បានកត់សម្គាល់ឃើញការពឹងផ្អែកក្នុងកាលៈទេសៈពិសេសរបស់គណៈកម្មាធិការខេត្ត លើថវិកាសេសសល់ដែលមិនគ្រប់គ្រាន់ ពីផ្នែកសេវាសង្គមទូទៅ ជាជាងពឹងផ្អែកលើថវិកាប្រចាំឆ្នាំរបស់ខ្លួនផ្ទាល់ បំផ្លាញដល់ទំហំ និងនិរន្តភាពនៃការងាររបស់គេ។ កង្វះការតម្រែតម្រង់ពីគណៈកម្មាធិការថ្នាក់ជាតិប៉ះពាល់បន្ថែមទៀតដល់ប្រសិទ្ធភាពការងាររបស់គេ។ NCCT បានបន្តចេញរបាយការណ៍ប្រចាំឆ្នាំ ស្តីពីការងាររួមក្នុងការប្រឆាំងការជួញដូររបស់រដ្ឋាភិបាល។ ប៉ុន្តែ ដូចក្នុងឆ្នាំមុនៗដែរ របាយការណ៍នោះមិនបានធ្វើបានជិតដល់ទេ ដោយសារការប្រមូលទិន្នន័យមិនគ្រប់គ្រាន់។ ពីរឆ្នាំមកហើយដែលរដ្ឋាភិបាលបានរៀបចំវេទិកាអន្តរសាសនា ស្តីពីការប្រយុទ្ធប្រឆាំងនឹងការជួញដូរ ដោយមានការចូលរួមនៃមន្ត្រីរដ្ឋាភិបាល និងមេដឹកនាំសាសនារាប់ពាន់នាក់ទៀត។

ក្រសួងការងារមានផែនការសកម្មភាពដោយឡែកមួយ ដើម្បីកាត់បន្ថយពលកម្មកុមារ និងទាសភាពបំណុល នៅក្នុងវិស័យផ្តល់សេវាកម្ម កសិកម្ម រ៉ែ និងថាមពល នៅត្រឹមឆ្នាំ ២០២៥ តាមរយៈការលើកកម្ពស់ការយល់ដឹង សកម្មភាពតាមផ្លូវច្បាប់ និងការសហការជាមួយសង្គមស៊ីវិល ដោយទទួលថវិកាមួយផ្នែកពីថវិកាជាតិ។ មិនដូចឆ្នាំមុនៗទេ រដ្ឋាភិបាលមិនបានរាយការណ៍ពីការធ្វើការស៊ើបអង្កេតឬកាត់ទោសអ្នកជ្រើសរើសពលករ ដែលបានប្រព្រឹត្តខុសច្បាប់នាំឲ្យមានឬពាក់ព័ន្ធការជួញដូរ ។ មន្ត្រី និងអ្នកសង្កេតការណ៍មកពី NGO បានកត់សម្គាល់ឃើញពីការខកខានរបស់មន្ត្រីធ្វើការផ្នែកការងារ នៅក្នុងការធ្វើអធិការកិច្ចបានគ្រប់គ្រាន់លើក្រុមហ៊ុនឯកជនដែលជ្រើសរើសមនុស្សធ្វើការ និងសមត្ថភាពនៃក្រុមហ៊ុនទាំងនេះនៅក្នុងការអោយឈ្មួញកណ្តាលក្រៅស៊ីឈ្មោះរបស់គេ បានបន្តធ្វើការកេងប្រវ័ញ្ចកម្លាំងពលកម្មយ៉ាងរាលដាល។ ក្រុមហ៊ុនទាំងនេះខ្លះ តាមសេចក្តីរាយការណ៍មក មានការពាក់ព័ន្ធដោយផ្ទាល់ នៅក្នុងការជ្រើសរើសមនុស្សដោយឆបោក ដែលជាការនាំឲ្យមានការជួញដូរមនុស្ស។

រដ្ឋាភិបាលបានបន្តធ្វើសកម្មភាពលើកកម្ពស់ការយល់ដឹង ដោយរួមមានតាមរយៈ "ព្រឹត្តិការណ៍ផ្សព្វផ្សាយ"ព័ត៌មាន ដោយ គជបជ ចំនួនជាង ៣៣០០០ និងវេទិកាសាធារណៈចំនួន ២៥ ០០០។ អគ្គ

នាយកដ្ឋានអន្តោប្រវេសន៍ បានចេញបណ្ណអនុញ្ញាតឆ្លងព្រំដែនចំនួន ៩២ ០៨១ ដល់ប្រជាជនកម្ពុជាដែលរស់នៅតំបន់ព្រំដែនភាគខាងលិច ដើម្បីឲ្យគេធ្វើចំណាកស្រុកទៅរកការងារធ្វើនៅប្រទេសថៃដោយសុវត្ថិភាព។ តាមសេចក្តីរាយការណ៍មក ក្រសួងការងារបានផ្តល់ការពន្យល់ណែនាំមុនពេលចេញដំណើរដល់ប្រជាជនកម្ពុជាចំនួន ៦៩ ០០០ នាក់ ដែលធ្វើចំណាកស្រុកទៅបរទេស ដើម្បីរកការងារធ្វើ។ ប៉ុន្តែតាមសេចក្តីរាយការណ៍មក ប្រជាជនក្កុជាជាច្រើនមិនដឹងពីវិធីដាក់ពាក្យសុំឯកសារធ្វើដំណើរ ឬថាវាអស់ថ្លៃប៉ុន្មានទេ ដែលជាការធ្វើឲ្យគេប្រឈមនឹងគ្រោះថ្នាក់ខ្ពស់ដោយធ្វើដំណើរតាមមធ្យោបាយអាចងាយរងគ្រោះ។ រដ្ឋាភិបាលមិនបានចាត់វិធានការ គ្រប់គ្រាន់នៅក្នុងការផ្សព្វផ្សាយព័ត៌មាននេះទេ។ ក្រសួងការបរទេសបាន បន្តអនុវត្តវិធានការត្រួតពិនិត្យផ្នែកកុងស៊ុល ដើម្បីកាត់បន្ថយការជួញដូរផ្លូវភេទ និងការជួញដូរពលកម្ម លើស្ត្រីកម្ពុជា តាមរយៈការរៀបការដោយបង្ខំ និងដោយបោកបញ្ឆោត ដោយរួមមានការពិនិត្យវាយតម្លៃអ្នកដាក់ពាក្យសុំ ដោយផ្ទៀងផ្ទាត់ជាមួយប្រវត្តិរូបរបស់ជនរងគ្រោះដោយការជួញដូរ ដែលត្រូវបានរៀបចំឡើងរួមគ្នាជាមួយប្រទេសចិន នៅឆ្នាំ ២០១៦។ តែក្រសួងការបរទេសមិនបានរាយការណ៍ថាបានបញ្ជូនមនុស្សដែលអាចជាជនរងគ្រោះទាំងនោះ ទៅសមត្ថកិច្ច ឬអោយទទួលសេវាការពារទេ។ រដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងចំនួន ២ ស្តីពីការជ្រើសរើសពលករ ជាមួយប្រទេសអារ៉ាប៊ីសាអ៊ូឌីត កិច្ចព្រមព្រៀងស្តីពីការជ្រើសរើសអ្នកបំរើការនៅតាមផ្ទះ ជាមួយក្រុងហុងកុង។ គជបជ ក៏បានចុះហត្ថលេខាផងដែរ លើផែនការសកម្មភាពជាមួយប្រទេសចិន ស្តីពីការកសាងសមត្ថភាព ការស៊ើបអង្កេត និងការការពាររួមគ្នា។

អ្នកសង្កេតការណ៍បានកត់សម្គាល់ឃើញលក្ខខណ្ឌទាមទារស្មុគស្មាញក្នុងការចុះបញ្ជី ហើយភាពជិតស្និទ្ធនៃមន្ត្រីរដ្ឋាភិបាលជាមួយនិយោជកខ្លះបានរាំងស្ទះដល់ការចុះធ្វើអធិការកិច្ចនៅតាមឡតដ្ឋក្បឿង ហើយបានរារាំងកម្មករឡដ្ឋបង្កើតអង្គការដែលធ្វើការដើម្បីសិទ្ធិរបស់ពួកគេ។ ក្រសួងទេសចរណ៍បានបើកសិក្ខាសាលាសំរាប់បុគ្គលិកសណ្ឋាគារ និងមន្ត្រីរដ្ឋាភិបាល ស្តីពីការការពារ ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ នៅក្នុងផ្នែកបដិសណ្ឋារកិច្ច។ ដូចនៅក្នុងឆ្នាំមុនៗដែរ ជាទូទៅ រដ្ឋាភិបាលផ្តោតសំខាន់លើការរារាំងទេសចរណ៍ផ្លូវភេទលើកុមារ ជាជាងយុទ្ធនាការដៅលើមនុស្សនៅក្នុងប្រទេសដែលជាប្រភពធំជាងគេនៃតម្រូវការលើការជួញដូរផ្លូវភេទលើកុមារ នៅកម្ពុជា។ អាជ្ញាធរបានរាយការណ៍មកថាបានចាប់ខ្លួនជន

សង្ស័យជាជនបរទេសចំនួន ៨ នាក់ ដែលត្រូវបានសង្ស័យថា បានធ្វើទោសចរណ៍ផ្លូវភេទលើកុមារ (៥ នាក់នៅឆ្នាំ ២០១៧ និង ១២ នាក់ នៅឆ្នាំ ២០១៦) តែមិនបានរាយការណ៍ថា តុលាការបានកាត់ទោស ឬដាក់ទោសលើជនណាមួយនៅក្នុងករណីទាំងនេះឬយ៉ាងណានោះទេ។ អ្នកជំនាញនៅក្នុងស្រុកបាន បង្ហាញកង្វល់លើការខកខានជាបន្តរបស់រដ្ឋាភិបាល ក្នុងការដាក់ទណ្ឌកម្មឲ្យបានសមស្រប លើជន បរទេសដែលទិញកុមារមករួមភេទក្នុងអំពើជួញដូរផ្លូវភេទ។

## លក្ខណៈទូទៅនៃការជួញដូរ

ដូចដែលត្រូវបាននិយាយនៅក្នុងរបាយការណ៍ នៅក្នុងរយៈពេល ៥ ឆ្នាំកន្លងទៅនេះ ជនល្មើស ក្នុងការជួញដូរ ធ្វើការជួញដូរពលកម្ម និងជួញដូរផ្លូវភេទលើបុរស នារី និងកុមារកម្ពុជា នៅក្នុងប្រទេស និងនៅបរទេស។ គេថែមទាំងជួញដូរជនរងគ្រោះមកពីប្រទេសដទៃផងដែរ នៅកម្ពុជា ហើយគេប្រើ ប្រទេសកម្ពុជាធ្វើជាប្រទេសឆ្លងកាត់ សម្រាប់ជួញដូរជនរងគ្រោះពីប្រទេសដទៃ ទៅកាន់កន្លែងផ្សេងទៀត នៅអាស៊ី។ ប្រជាជនកម្ពុជាពេញវ័យនិង កុមារកម្ពុជាធ្វើចំណាកស្រុកទៅប្រទេសដទៃទៀតនៅក្នុងតំបន់ ហើយក្នុងចំនួនកាន់តែច្រើនឡើង ទោមផ្សឹមបូព៌ា ដើម្បីរកការងារធ្វើ។ ជនប្រព្រឹត្តិការជួញដូរបង្ខំឲ្យពួកគេ ជាច្រើនធ្វើការក្នុងទូកនេសាទ ក្នុងវិស័យកសិកម្ម តាមការដ្ឋានសំណង់ នៅតាមរោងចក្រ បម្រើ នៅក្នុង ផ្ទះដូចជាទាសករ ដោយភាគច្រើនដោយសារការជាប់ទាសភាពបំណុល ឬត្រូវបានជួញដូរផ្លូវភេទ ។ អ្នក ធ្វើចំណាកស្រុកដែលប្រើមធ្យោបាយធ្វើចំណាកស្រុកមិនធម្មតា ដោយជាញឹកញាប់ មានការជួយពីមេ ខ្យល់ដែលគ្មានច្បាប់អនុញ្ញាត ងាយរងគ្រោះដោយការជួញដូរ ថ្វីបើអ្នកដែលប្រើក្រុមហ៊ុនមានច្បាប់ អនុញ្ញាត ក៏ច្រើនតែក្លាយជាអ្នករងគ្រោះដោយការបង្ខំឲ្យធ្វើពលកម្ម ឬការជួញដូរផ្លូវភេទដែរ។ ប្រជាជន កម្ពុជានៅក្នុងកម្មវិធីពលករជាភ្ញៀវរបស់រដ្ឋាភិបាលជប៉ុន បាននិយាយពីការបង្ខំអោយធ្វើការ។ កុមារនៅ ក្នុងគ្រួសារក្រីក្រងាយរងគ្រោះខ្លាំងដោយការបង្ខំឲ្យធ្វើពលកម្ម ជាញឹកញាប់ ដោយមានការត្រូវរ៉ូវជាមួយ គ្រួសាររបស់គេ រួមមានការបង្ខំឲ្យធ្វើជាឈ្នួលបំរើតាមផ្ទះ និងត្រូវបានបង្ខំឲ្យដើរសុំទាន ឬដើរលក់របស់នៅ តាមផ្លូវនៅប្រទេសថៃ និងប្រទេសវៀតណាម។ ពលករចំណាកស្រុកខ្មែរដែលគ្មានឯកសារ ហើយធ្វើការ នៅប្រទេសថៃ ដែលមានចំនួនរហូតដល់ ៤០% នៃប្រជាជនកម្ពុជាចំនួន ១,៥ លាននាក់នៅប្រទេសថៃ ងាយរងគ្រោះនឹងការជួញដូរ ដោយសារការស្នាក់នៅខុសច្បាប់ ក៏ដូចជាប្រជាជនកម្ពុជាដែលត្រូវបានប ណ្តេញចេញពីប្រទេសវៀតណាម ដែរ។ ជនល្មើសបន្តជ្រើសរើសកុមារា និងបុរសកម្ពុជាក្នុងចំនួនច្រើន

នៅក្នុងប្រទេសថៃ អោយធ្វើការនៅក្នុងទូកនេសាទរបស់ថៃ នៅក្នុងសមុទ្រអន្តរជាតិ។ ជនរងគ្រោះខ្មែរ ដែលបានគេចចេញពីជនល្មើសត្រូវបានគេរកឃើញនៅក្នុងប្រទេសម៉ាឡេស៊ី ឥណ្ឌូនេស៊ី Mauritius ហ្វីជី សេណេហ្គាល់ អាហ្វ្រិកខាងត្បូង និងប្រទេស Papua New Guinea។ បុរសខ្មែរនៅលើទូកនេសាទថៃ បាននិយាយពីវិធីជ្រើសរើសមនុស្សអោយធ្វើការដោយការបោកបញ្ឆោត ការធ្វើបាបយ៉ាងខ្លាំង ការឲ្យថ្លៃឈ្នួលមិនគ្រប់ ឬមិនមានប្រាក់ឈ្នួល ការមិនសូវទទួលបានការថែទាំជម្ងឺ និងការ បង្ខាំងឲ្យនៅតែលើទូករាប់ឆ្នាំ ។ នារីនៅតាមជនបទក្នុងចំនួនច្រើន ត្រូវបានគេទាក់ទងក្រោមលេសកុហក ឲ្យរៀបការជាមួយបុរសចិន ។ ពួកគេច្រើនតែជាប់បំណុលរហូតដល់ ២០ ០០០ ដុល្លាទៅមេខ្យល់ ដែលជួយរត់ការក្នុងការបានរៀបការនេះ។ បុរសចិនបង្ខំឲ្យពួកគេខ្លះធ្វើការនៅក្នុងរោងចក្រ ឬបង្ខំឲ្យធ្វើជាស្រីពេស្យា ដើម្បីដោះបំណុលនេះ។ ស្ត្រីខ្មែរដែលសុខចិត្តពរពោះឲ្យគ្រួសារចិន ងាយរងនឹងការចាប់ឃុំឲ្យនៅមួយកន្លែង និងបម្រើនៅក្នុងផ្ទះដូចជាទាសករ។ ទោះបីជាមិនសូវមានព័ត៌មានច្បាស់លាស់ក្តី តែពួកជ្រុលនិយម ដែលប្រើហឹង្សា តាមសេចក្តីរាការណ៍មក បានប្រើវិធីបោកបញ្ឆោតក្នុងការជើរើសមនុស្ស ដើម្បីទាក់ទាញកុមារមួយចំនួនតូចឲ្យចូលរួមនៅក្នុងជំរឹហ្វឹកហ្វឺនពួកបះបោរប្រដាប់អាវុធ នៅតំបន់ជនបទនៃប្រទេសថៃ។ មនុស្សគ្មានរដ្ឋ ពោលគឺក្រុមអាណិកជនវៀតណាម ងាយប្រឈមនឹងការជួញដូរ ដោយសារគេខ្វះឯកសារកំណត់អត្តសញ្ញាណចាំបាច់ សម្រាប់ទទួលបានការងារត្រឹមត្រូវ ការសិក្សា ការចុះបញ្ជីអាពាហ៍ពិពាហ៍ ការកាត់ក្តីក្នុងតុលាការ ឬសិទ្ធិលើកម្មសិទ្ធិដីធ្លី។

ម្ចាស់ឡតដ្ឋធ្វើឲ្យបុរស នារី និងកុមារយ៉ាងហោចណាស់ចំនួន ១០ ០០០ នាក់ ដែលច្រើនតែគ្រួសារទាំងមូល ស្ថិតនៅក្រោមការបង្ខិតបង្ខំតគ្នា ដោយសារបំណុល ដោយសារគេទិញបំណុលដែលអ្នកទាំងនោះជំពាក់ស្រាប់ ឬដោយសារតម្រូវឲ្យគេខ្ចីបំណុលថ្មីធ្វើជាលក្ខខណ្ឌឲ្យទទួលបានការងារធ្វើ ឬដើម្បីបំពេញការចំណាយដោយសាររងរបួស នៅក្នុងពេលធ្វើការ។ ការសិក្សាមួយរបស់ NGO ដែលត្រូវបានធ្វើនៅក្នុងឆ្នាំ ២០១៧ បានរកឃើញថា ជិត ១០០% នៃកន្លែងឡតដ្ឋដែលត្រូវបានអង្កេតទៅលើ នៅទូទាំងប្រទេស មានសូចនាករនៃការបង្ខំឲ្យធ្វើការ តាមរយៈការបង្ខិតបង្ខំក្រោមបំណុល។ បណ្តាញនៃអ្នកផ្តល់កម្ចីឯកជន និងស្ថាប័នមីក្រូហិរញ្ញវត្ថុដែលគាបយកការប្រាក់ខ្ពស់ ហើយដែលមានច្រើន ហើយមិនសូវស្ថិតនៅក្រោមច្បាប់ទំលាប់គ្រប់គ្រង មានចំណែកធ្វើឲ្យមានស្ថានភាពបែបនេះ ដោយដើរប្រកាសពីការផ្តល់កម្ចីដល់គ្រួសារ នៅតាមសហគមន៍ខ្សត់ខ្សោយ ហើយភ្ជាប់ពួកគេទៅនឹងកន្លែងឡតដ្ឋ។ គ្រួសារកសិករនៅតាមជនបទប្រឈមខ្លាំងនឹងទម្រង់នៃពលកម្មដោយបង្ខំបែបនេះ ដោយសារសេដ្ឋកិច្ចគ្រួសារមានការ

លំបាក បន្ទាប់ពីមានបម្រែបម្រួលអាកាសធាតុ ទឹកភ្លៀងធ្លាក់មិនទៀងទាត់ ហើយនិងការខូចដំណាំបាន ជំរុញឲ្យកសិករជាច្រើនខ្ចីបុលទាំងនេះ ដើម្បីការស្រោចស្រព ឬទិញថ្នាំសម្លាប់សត្វល្អិត ម្ចាស់ឡឥដ្ឋច្រើន ទិញបំណុលទាំងនេះ ដើម្បីឲ្យពួកគេមកធ្វើការឲ្យខ្លួន។ រដូវវស្សាវែងពន្យារដំណើរការហាលឥដ្ឋ ដែលជាការបន្ថយប្រាក់បៀវត្សរបស់កម្មករឡឥដ្ឋដែលនៅជាប់បំណុល ហើយរឹតតែជំរុញកម្មករទាំងនោះជំពាក់ថៅកែកាន់តែច្រើនឡើង។ ដើម្បីកុំឲ្យកម្មករចេញពីកន្លែង បង្ខំឲ្យធ្វើការរបស់គេ ថៅកែឡខ្លះ តាមសេចក្តីរាយការណ៍មកថា អនុញ្ញាតឲ្យតែសមាជិកខ្លះក្នុងគ្រួសារឈប់សម្រាក នៅថ្ងៃបុណ្យ ឬទៅមើលជម្ងឺ នៅពេលណាមួយ។ កម្មករខ្លះបាននិយាយពីការបន្តរងការឃុំខ្លួន ឬការបង្ខំឲ្យធ្វើការ នៅកន្លែងឡឥដ្ឋ ទោះបីជាគេបានសងបំណុលយូរហើយមកហើយក៏ដោយ។ ជនប្រព្រឹត្តការជួញដូរថែមទាំងដាក់ឲ្យកុមារអាយុត្រឹម ១៣ ឆ្នាំ នៅបម្រើដូចជាទាសករ ហើយធ្វើការនៅក្បែរប្រាំង ឬក្នុងទូកនេសាទសមុទ្រ នៅតាមហាងខារ៉ាអូខេ និងនៅតាមចំការដំឡូង ដើម្បីសងបំណុលរបស់គ្រួសារ។ សហគមន៍ដែលត្រូវធ្វើការផ្លាស់ទីលំនៅដោយសារការកាប់ឈើខុសច្បាប់ ដើម្បីផ្គត់ផ្គង់ឡឥដ្ឋដែលត្រូវការឈើដុតឡ ប្រហែលប្រឈមខ្លាំងនឹងការជួញដូរមនុស្ស ដោយរួមមាននៅក្នុងការកាប់ឈើតែម្តង និងនៅកន្លែងផ្សេងទៀត ដោយសារការលំបាកក្នុងជីវភាព ក្នុងស្ថានភាពនេះ។

ខេត្តក្រុងទាំង ២៥ របស់ប្រទេសកម្ពុជាគឺជាប្រភពនៃការជួញដូរមនុស្ស។ ការជួញដូរផ្លូវភេទច្រើនតែមានការលាក់បាំង។ កុមារី និងស្ត្រីខ្មែរ និងកុមារី និងស្ត្រីអាណិកជនវៀតណាមចេញពីតំបន់ជនបទ ទៅកាន់ទីក្រុង និងគោលដៅទេសចរ ជាទីដែលជនល្មើសជួញដូរផ្លូវភេទលើពួកគេទៅឲ្យផ្ទះបន ហើយជាញឹកញាប់ នៅតាមកន្លែងផ្តល់សេវាផ្លូវភេទលាក់កំបាំង នៅតាមបៀហ្គាដិន ហាងម៉ាសា ហាងខារ៉ាអូខេ កន្លែងលក់រាយ និងកន្លែងមិនមែនពាណិជ្ជកម្ម។ បុរសខ្មែរនៅក្នុងស្រុកគឺជាប្រភពសំខាន់នៃតម្រូវការលើការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារ តែបុរសមកពីតំបន់ផ្សេងទៀត នៅអាស៊ី អឺរ៉ុប សហរដ្ឋអាមេរិក អូស្ត្រាលី និងអាហ្វ្រិកខាងត្បូង ធ្វើដំណើរមកប្រទេសកម្ពុជា ដើម្បីធ្វើទេសចរណ៍ផ្លូវភេទលើកុមារ។ ការនេះរឹតតែធ្វើឲ្យមានភាពងាយស្រួលថែមទៀតសម្រាប់ការជួញដូរ ដោយការទាក់ទងតាមប្រព័ន្ធផ្សព្វផ្សាយសង្គម។ កុមាររាប់ពាន់នាក់ នៅតំបន់ក្រុង ដែលត្រូវបានគ្រួសារទុកចោល នៅពេលគេចេញទៅធ្វើការនៅបរទេស ងាយរងគ្រោះដោយការជួញដូរផ្លូវភេទ និងការបង្ខំអោយធ្វើពលកម្ម។ ស្ត្រីនិងកុមារវៀតណាម ដែលភាគច្រើនជាជនរងគ្រោះដោយការបង្ខិតបង្ខំដោយសារការជំពាក់គេ ធ្វើដំណើរមកប្រទេសកម្ពុជា ហើយរងគ្រោះដោយការជួញដូរផ្លូវភេទ។ NGO បានរាយការណ៍ពីជនល្មើសដឹកជញ្ជូនជនរងគ្រោះវៀតណាម ឆ្លង

កាត់ប្រទេសកម្ពុជា មុនពេលរងការកេងប្រវ័ញ្ច នៅប្រទេសថៃ និងប្រទេសម៉ាឡេស៊ី។ ជនល្មើសនៅកម្ពុជាច្រើនតែជាសមាជិកគ្រួសារ ឬសមាជិកសហគមន៍ ឬជាបណ្តាញតូចៗនៃឈ្មួញកណ្តាលមកពីក្រៅ។ មជ្ឈមណ្ឌលកុមារកំព្រាកម្ពុជាខ្លះទិញកុមារក្នុងមូលដ្ឋាន ពីគ្រួសារដែលមានភាពខ្សត់ខ្សោយ ហើយឲ្យគេរស់នៅដោយគ្មានអាហារូបត្ថម្ភគ្រប់គ្រាន់ និងគ្មានអនាម័យ នៅក្នុងមជ្ឈមណ្ឌល ដើម្បីទាក់ទាញ និងទទួលផលចំណេញពីអំណោយសប្បុរស។ កុមារទាំងនេះខ្លះប្រឈមនឹងការជួញដូរផ្លូវភេទ និងការដាក់ឲ្យបម្រើការងារក្នុងផ្ទះដូចជាទាសករ ដោយសារខ្វះការត្រួតមើលរបស់រដ្ឋាភិបាល លើដំណើរការសុំកូនក្មេង។ អំពើពុករលួយយ៉ាងរាលដាលជួយជំរុញបទល្មើសជួញដូរ។ តាមសេចក្តីរាយការណ៍មក នគរបាលបានសុំទិញការរួមភេទជាមួយកុមារ។ មន្ត្រីពុករលួយសម្រួលការជួញដូរឆ្លងកាត់ព្រំដែន រារាំងដំណើរជឿនលឿនទៅមុខក្នុងការស៊ើបអង្កេត និងការកាត់ទោស ហើយក្នុងករណីខ្លះ ទទួលបានផលចំណេញដោយផ្ទាល់ពីកន្លែងដែលត្រូវបានសង្ស័យថា ធ្វើការជួញដូរ៕

## ផែនការសកម្មភាពប្រឆាំងការជួញដូរមនុស្ស ឆ្នាំ ២០១៩ -២០២០ សម្រាប់កម្ពុជា

សូមមើលអនុសាសន៍ខាងក្រោមសម្រាប់បំណងក្នុងការជំរុញការខិតខំក្នុងការប្រឆាំងនឹងការជួញដូរមនុស្សរបស់រដ្ឋាភិបាលកម្ពុជា នៅឆ្នាំបន្ទាប់ទៀតៈ

១) គោរពដំណើរការត្រឹមត្រូវ បង្កើនការខិតខំក្នុងការស៊ើបអង្កេត និងនាំខ្លួនយកមកកាត់ទោស ដាក់ទោស និងដាក់ទណ្ឌកម្មឲ្យបានគ្រប់គ្រាន់ ចំពោះជនល្មើសក្នុងការជួញដូរផ្លូវភេទនិងជួញដូរពលកម្ម រួមទាំងមន្ត្រីឃុបឃិត ដោយដាក់ទោសឲ្យជាប់ពន្ធនាគារធ្ងន់ធ្ងរ។

២) អនុញ្ញាតអោយមានការប្រើបច្ចេកទេសស៊ើបអង្កេតសំងាត់ នៅក្នុងប្រតិបត្តិការប្រឆាំងការជួញដូរ។

៣) ពង្រឹងការខិតខំក្នុងការអនុវត្តពេញលេញនូវពិធីសារថ្មីទូទាំងប្រទេស សម្រាប់រកមើលជនរងគ្រោះនៅក្នុងចំណោមក្រុមដែលងាយរងគ្រោះ ដោយការងារនេះត្រូវប្រព្រឹត្តទៅដោយសកម្ម ហើយបង្រៀនមន្ត្រីអោយយល់ពីខដែលចែងនៅក្នុងច្បាប់នេះ ។

៤) បង្កើនការធ្វើអធិការកិច្ចការងារ នៅកន្លែងការងារដែលមានការប្រឈមខ្លាំង ពិសេសនៅតាមឡឥដ្ឋ កន្លែងនេសាទ និងចំការធំៗ ដោយផ្តោតសំខាន់លើការរកមើលទាសភាពបំណុល (Debt bondage)។

៥) បង្កើនសេវាសម្រាប់ជនរងគ្រោះជាបុរស ពិសេសបុរស និងកុមារដែលត្រូវបានគេកេងប្រវ័ញ្ចនៅតាមទូកនេសាទពាណិជ្ជកម្ម។

៦) បង្កើនការតាមមើល និងត្រួតពិនិត្យលើស្ថាប័នឲ្យកម្ចី ដោយរួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុឯកជន ដើម្បីកាត់បន្ថយភាពងាយរងគ្រោះនឹងការបង្ខំដោយសារបំណុល នៅក្នុងចំណោមក្រុមដែលមានជីវភាពខ្សត់ខ្សោយ។

៧) បង្កើនការខិតខំឲ្យមានការចូលរួមរបស់ជនរងគ្រោះ នៅក្នុងដំណើរក្តីព្រហ្មទណ្ឌ និងដំណើរក្តីរដ្ឋប្បវេណី ដោយរួមមានការផ្តល់ការអនុញ្ញាតឲ្យធ្វើការ ស្នាក់នៅបណ្តោះអាសន្ន និងឋានៈស្ថានភាពអន្តោ

ប្រវេសន៍ដទៃទៀតដែលចាំបាច់ ដល់ជនបរទេសជាជនរងគ្រោះ ដែលចង់ស្នាក់នៅក្នុងប្រទេសនៅក្នុងអំឡុងពេលដំណើរការក្តី ។

៨) កែប្រែច្បាប់ដែលអនុញ្ញាតឲ្យមានការផ្តល់សំណងនៅពេលជនល្មើសត្រូវបានដាក់ទោស បង្កើតហើយបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ ដែលធ្វើការទាក់ទងនឹងនិតិវិធីការងារជាបទដ្ឋានសំរាប់គណនា និងផ្តល់សំណង។

៩) បង្កើតឲ្យមាន ហើយធ្វើការបែងចែកធនធាន ដើម្បីអនុវត្តនិតិវិធីជាប្រព័ន្ធ នៅតាមបេសកកម្មការដើម្បីជួយជនរងគ្រោះខ្មែរនៅបរទេស រួមទាំងនៅក្នុងប្រទេសដែលគ្មានតំណាងទូតកម្ពុជា។

១០) ពង្រឹងការខិតខំក្នុងការត្រួតពិនិត្យក្រុមហ៊ុនជ្រើសរើសកំលាំងពលកម្មឯកជន និងសាខារបស់គេ ដើម្បីរកមើលការជ្រើសរើសដែលមានលក្ខណៈបន្លំឬការជួញដូរដទៃទៀត។

១១) បង្កើនការយល់ដឹងរបស់សាធារណជនលើបែបបទដាក់ពាក្យសុំឯសារធ្វើដំណើរសមស្រប ដើម្បីសម្រួលដល់ការធ្វើចំណាកស្រុកដោយស្របច្បាប់ និងប្រកបដោយសុវត្ថិភាព។

១២) អនុវត្តប្រព័ន្ធមួយសម្រាប់តាមដាន ប្រមូល និងរាយការណ៍ទិន្នន័យស្តីពីការកាត់ទោសប្រឆាំងការជួញដូរ និងការងារការពារជនរងគ្រោះ ផ្សព្វផ្សាយទិន្នន័យនៅក្នុងចំណោមស្ថាប័នរដ្ឋដែលមានការពាក់ព័ន្ធ ដើម្បីការពារការសម្ងាត់ឯកជននិងអត្តសញ្ញាណរបស់ជនរងគ្រោះ។

១៣) ពង្រឹងការខិតខំដើម្បីបញ្ចូលគំនិតរបស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងគោលនយោបាយសំរាប់ផ្ទេរការគ្រប់គ្រងជាផ្លូវការ លើជនរងគ្រោះជាកុមារ។

១៤) បង្កើនការចំណាយធនធានលើនគរបាលប្រឆាំងការជួញដូរមនុស្ស ដើម្បីសម្រួលដល់ការតាមដានចុងចោទ ដែលត្រូវបានដោះលែងក្រោមការឃ្លាំមើលរបស់តុលាការ រហូតដល់មានសវនាការ ។